# អង្គការមរតក

របាយការណ៍ប្រចាំឆ្នាំ ២០២២



## ទស្សនៈវិស័យ

អង្គការមរតក ស្រមៃមើលសហគមន៍ជនបទក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋមានសិទ្ធិ និងឱកាសស្មើគ្នាក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់ការលើកកម្ពស់គុណភាពជីវិតពួកគេរស់នៅប្រកបដោយសន្តិភាព។

## បេសកកម្ម

ដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រជាជនក្រីក្រក្នុងសហគមន៍ឆ្នេរនៃប្រទេសកម្ពុជា ពង្រឹងសាមគ្គីភាព និងបង្កើតភាពជាម្ចាស់ តាមរយៈការកសាងសមត្ថភាព គាំទ្រគំនិតផ្តួចផ្តើមរបស់ពួកគេ និងសម្របសម្រួលកិច្ចសន្ទនារវាងតួអង្គពាក់ព័ន្ធ។

## គោលបំណង

ដើម្បីលើកកម្ពស់ការពង្រឹងសមត្ថភាពសហគមន៍ឆ្ពោះទៅរកការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច តាមរយៈការពង្រឹងសមត្ថភាព ក្រុមសហគមន៍ (CBO និងក្រុមចិញ្ចឹមជីវិត) ដើម្បីចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អក្នុងមូលដ្ឋាន។

□□□□□□□

### អង្គការ មរតក ជឿជាក់ថា៖

1. តម្លាភាព និងគណនេយ្យភាព បង្កើតការជឿទុកចិត្តក្នុងចំណោមបុគ្គលិក និងអ្នកពាក់ព័ន្ធ ហើយនាំទៅដល់ ការគ្រប់គ្រងអង្គភាពរឹងមាំ។
2. ការអភិវឌ្ឍន៍សមត្ថភាពអាចឱ្យអង្គការ និងសហគមន៍ឆ្លើយតបទៅនឹងតម្រូវការផ្លាស់ប្តូរ និងនិរន្តរភាព។
3. ការលើកកម្ពស់ជីវភាពសហគមន៍ កើតចេញពីកិច្ចសហការល្អរវាងតួអង្គពាក់ព័ន្ធ។
4. ភាពជាម្ចាស់លើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាពនៃការអនុវត្ត។
5. ការចូលរួម ការផ្តួចផ្តើមគំនិត និងសមភាពយេនឌ័រ អាចឱ្យយើងប្រមូលធនធានដែលមាននិងសម្រាប់ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។



### បុគ្គលិក អង្គការមរតក

# អង្គការមរតក
MORODOK ORGANIZATION

## មាតិកា


ប្រវត្តិសង្ខេបរបស់មរតក ........ 4

សាររបស់នាយកប្រតិបត្តិ ........ 5

អក្សរកាត់ដែលប្រើក្នុងរបាយការណ៍នេះ ........ 6

សមិទ្ធិផលគម្រោងក្នុងឆ្នាំ ២០២២ ........ 7

ការពង្រឹងជីវភាពសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិជុំវិញឆ្នេរសមុទ្រកំពង់សោម ........ 7

សហគមន៍ជុំវិញឆ្នេរកំពង់សោម ........ 9

ការពង្រឹងសហគមន៍សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅប្រកបដោយនិរន្តរភាព ........10

ករណីសិក្សាក្នុងការលើកកម្ពស់ជីវភាព ........11

គំនូសរចនាសម្ព័ន្ធអង្គការមរតក ........11

ផែនការយុទ្ធសាស្ត្រ ២០២៣-២០២៨ ........12

តំបន់គោលដៅមរតក និងអង្គការតាមសហគមន៍ ........13

របាយការណ៍ហិរញ្ញវត្ថុ ........14



បោះពុម្ពនៅទីក្រុងភ្នំពេញ


© អង្គការ មរតក 2023


*រូបថតក្របមុខ៖ សកម្មភាពក្រុមកែច្នៃធនធានជលផលសម្ងួតត្រីនៅឃុំរត្រេះ ។*

នៅក្នុងភាសាខ្មែរ "**មរតក**" មានន័យថា "**កេរ្តិ៍ដំណែល**" ។ យោងតាមអនុក្រឹត្យរបស់ "**មរតក**" វាក៏ជាអក្សរកាត់សម្រាប់ឃ្លាមួយដែលមានន័យថា "**មាគ៌ា**ឆ្ពោះទៅរកការ**រីកចម្រើន**ប្រកបដោយ**តម្លាភាព** សម្រាប់ជា **កេរ្តិ៍ដំណែល**នៃមនុស្សជំនាន់ក្រោយ"។

# ប្រវត្តិសង្ខេបរបស់មរតក

**មរតក** គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលធ្វើការជាមួយសហគមន៍ជនបទជុំវិញឆ្នេរសមុទ្រកំពង់សោម នៃប្រទេសកម្ពុជា។ គ្រាមុន**មរតក**ជាកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ គណៈកម្មាធិការសេវាកម្មមិត្តអាមេរិក (American Friends Service Committee, AFSC)។ ក្នុងខែកញ្ញាឆ្នាំ១៩៩៧ អង្គការAFSCបានចាប់ផ្តើមការងាររបស់ខ្លួនអនុវត្តន៍កម្មវិធីចិញ្ចឹមជីវិតចំរុះប្រកបដោយនិរន្តរភាព (Iintegrated Sustainable Livelihoods Program, ISLP) នៅស្រុកស្រែអំបិល ខេត្តកោះកុងដែលជាតំបន់ដាច់ស្រយាលនិងអសន្តិសុខ។ AFSC/ISLP ដើមឡើយបានផ្តល់សេវាកម្មចំរុះផ្នែករួមទាំង កសិកម្ម ប្រព័ន្ធធារាសាស្ត្រ ឥណទាន សុខភាពបឋម និងកម្មវិធីអប់រំ។ នៅក្នុងឆ្នាំ ២០០១ កម្មវិធីនេះបានផ្តោតលើការជួយ សហគមន៍ក្នុងការគ្រប់គ្រង និងការពារធនធានធម្មជាតិ (Natural Resource Management, NRM) និងកែលម្អជម្រើសមុខរបរចិញ្ចឹមជីវិត (Livelihoods)។

នៅឆ្នាំ២០០៣AFSC/ISLPត្រូវបានគ្រប់គ្រងដោយបុគ្គលិកខ្មែរទាំងស្រុង។ មកទល់ឆ្នាំ២០០៤AFSC/ISLPបានរៀបចំអនុម័តគោលនយោបាយហិរញ្ញវត្ថុដើម្បីឱ្យបុគ្គលិកខ្មែរអាចគ្រប់គ្រងថវិកាផ្ទាល់ខ្លួនរបស់ពួកគេនិងរៀបចំខ្លួនប្រែក្លាយជាអង្គការមូលដ្ឋានក្នុងស្រុកយ៉ាងពេញលេញ។ ក្នុងឆ្នាំ 2008 បុគ្គលិកខ្មែរនៃអង្គការAFSC/ISLPបានរៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្ទៃក្នុងដើម្បីស្វែងយល់ពីគោលគំនិតអំពីរបៀបក្លាយខ្លួនជាអង្គការក្នុងស្រុកឈ្មោះថា "**មរតក**" ដោយបានរៀបចំនិងអនុវត្តន៍ផែនការ "មូលដ្ឋានីយកម្ម" (Localization plan) រយៈពេល៣ឆ្នាំ។ បុគ្គលិកAFSC/ISLP បានបង្កើតចក្ខុវិស័យ និងបេសកកម្មរបស់ "**មរតក**" ហើយបានចាប់ផ្តើមអនុវត្តន៍ដំណើរការផ្លាស់ប្តូរដោយបានបង្កើតអត្តសញ្ញាណ លក្ខន្តិកៈ គោលនយោបាយ រចនាសម្ព័ន្ធអភិបាលកិច្ច និងផែនការកសាងសមត្ថភាពអង្គការ។ នៅខែមេសា ឆ្នាំ ២០១១ ក្រុមកម្មវិធី ISLP បានចុះឈ្មោះ នៅក្រសួងមហាផ្ទៃទៅជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ក្រោមឈ្មោះថា "**មរតក**"។

នៅថ្ងៃទី០១ខែតុលា ឆ្នាំ២០១១ អង្គការAFSCបានប្រគល់កម្មវិធី"ISLP"ទៅអង្គការ "**មរតក**"។ ពិធីប្រគល់ត្រូវបានប្រារព្ធឡើងនៅស្រែអំបិល នៅថ្ងៃទី០៥ខែតុលា ឆ្នាំ២០១១។ ចាប់តាំងពីពេលនោះមក "**មរតក**" បានបន្តធ្វើការក្នុងតំបន់ ដោយលើកទឹកចិត្តក្រុមសហគមន៍ឱ្យទទួលយកសិទ្ធិរបស់ពួកគេលើការប្រើប្រាស់ធនធានធម្មជាតិនិងការកែលម្អជីវភាពរស់នៅ។ បុគ្គលិក "**មរតក**" ធ្វើការជិតស្និទ្ធជាមួយអ្នកដឹកនាំសហគមន៍ ដោយជួយពួកគេក្នុងការលើកកម្ពស់ភាពជាម្ចាស់ក្នុងការអភិវឌ្ឍន៍សហគ្រាសសង្គម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ អង្គករ "**មរតក**"បន្តប្រមូលផ្តុំក្រុមសហគមន៍ឲ្យធ្វើការជាមួយមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន និងមន្ត្រីបច្ចេកទេស ដើម្បីជួយក្រុមសហគមន៍រៀបចំពាក្យសុំ និងសំណើរដាក់ជូនស្ថាប័នរដ្ឋថ្នាក់ខេត្ត/ជាតិ សុំសិទ្ធិលើការគ្រប់គ្រងធនធានសហគមន៍នៅតំបន់ឆ្នេរ កំពង់សោម នៃប្រទេសកម្ពុជា។



នៅខែតុលា ឆ្នាំ២០១១ AFSC បានប្រគល់គម្រោងISLP ជាផ្លូវការដល់បុគ្គលិកខ្មែ ដែលបានបង្កើតអង្គការ "**មរតក**" ។

# សារពីនាយកប្រតិបត្តិ



នៅឆ្នាំ២០២២ **មរតក** បានបង្កើតផែនការយុទ្ធសាស្ត្រថ្មីមួយ ហើយបានចាប់ផ្តើមគម្រោងថ្មីដ៏សំខាន់មួយដោយមានការគាំទ្រមូនិធិពី FELM ។ ការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្មីនេះបានបង្ហាញពីការបន្តនៃវិធីសាស្ត្របច្ចុប្បន្នរបស់ **មរតក** និងការណែនាំអំពីសមាសធាតុការងារថ្មីមួយចំនួន។

**មរតក** បន្តគាំទ្រគំនិតផ្តួចផ្តើមការធ្វើអាជីវកម្មរបស់អ្នកភូមិក្រីក្រ និងពង្រឹងបណ្តាញសហគមន៍លើការគ្រប់គ្រងធនធានធម្មជាតិ។ **មរតក** បន្តពង្រឹងសកម្មភាពចិញ្ចឹមជីវិតដែលមានស្រាប់តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលដល់សហគមន៍ទុកបង្វិល មជ្ឈមណ្ឌលពាណិជ្ជកម្មសហគមន៍ និងតំណាងក្រុមចាប់អារម្មណ៍។ មរតក បន្តគាំទ្រសហគមន៍នេសាទចំនួន ៨ សហគមន៍តំបន់ការពារចំនួន៨ និងសហគមន៍ព្រៃឈើចំនួន ៣ ដើម្បីរៀបចំផែនការគ្រប់គ្រង និងការពារធនធានធម្មជាតិក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមទាំងនេះមួយចំនួនក៏ចូលរួមក្នុងការរៀបចំសកម្មភាពទេសចរណ៍ធម្មជាតិតាមសហគមន៍ផងដែរ។

សមាសធាតុថ្មីនៃយុទ្ធសាស្ត្ររបស់ **មរតក**ពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការផ្តោតកាន់តែខ្លាំងលើសន្តិសុខស្បៀងនៃគ្រួសារជនពិការ (តាមរយៈការបង្កើតសួនបន្លែតាមផ្ទះ) ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ជនពិការនិងសមាជិកគ្រួសាររបស់គេនឹងត្រូវបានជួយឲ្យចូលរួមសកម្មភាពអភិវឌ្ឍន៍នានាដូចជាការធ្វើសួនបន្លែតាមផ្ទះ។ ប្រជាសហគមន៍នៅក្នុងឃុំទាំង១៤នឹងត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងការបង្កើតផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

នៅឆ្នាំ២០២២ **មរតក**ក៏បានធ្វើសំណើសម្រាប់ដំណាក់កាលបន្ទាប់នៃការងាររបស់ខ្លួនដែលគាំទ្រមូលនិធីដោយ Bread for the World (ប្រទេសអាល្លឺម៉ង់) ដែលនឹងចាប់ផ្តើមខែមេសា ឆ្នាំ 2023។ សមាសធាតុថ្មីនៃយុទ្ធសាស្ត្រនេះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគម្រោងសំណើថ្មីផងដែរ។ ដូចគ្នានេះផងដែរ ដំណាក់កាលថ្មីនៃការគាំទ្រមូលនិធិរបស់ WWF នឹងត្រូវចាប់ផ្តើមនៅខែកក្កដា ឆ្នាំ 2023។

**មរតក**សូមថ្លែងអំណរគុណដល់ដៃគូម្ចាស់ជំនួយទាំងអស់ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញ ជាពិសេសសហគមន៍មូលដ្ឋានដែលជួយផ្តល់កិច្ចសហប្រតិបត្តិការប្រកបដោយនិរន្តរភាព និងការប្តេជ្ញាចិត្តធ្វើឲ្យសម្រេចបានចំពោះគោលដៅអភិវឌ្ឍន៍រួមរបស់យើង។



អ៊ុង ទិវា (នាយកប្រតិបត្តិ)

អក្សរកាត់ប្រើក្នុងរបាយការណ៍នេះ

CBET ទេសចរណ៍ធម្មជាតិតាមសហគមន៍

CBO អង្គការសហគមន៍

CPA សហគមន៍តំបន់ការពារ

CRF ទុកបង្វិលសហគមន៍

NTFP អនុផលព្រៃឈើ

## ការពង្រឹងជីវភាពសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិជុំវិញឆ្នេរសមុទ្រកំពង់សោម

ប្រជាជនជនបទភាគច្រើនរស់នៅជុំវិញឆ្នេរសមុទ្រកំពង់សោម ពឹងផ្អែកលើធនធានធម្មជាតិ ដើម្បីបំពេញបន្ថែមជីវភាពរបស់ពួកគេ ដែលភាគច្រើនរស់ពឹងផ្អែកលើការធ្វើកសិកម្មបែបប្រពៃណី មុខរបរនេសាទត្រីនិងធនធានជលផលផ្សេងទៀត ព្រមទាំងផលិតផលព្រៃឈើជាច្រើនប្រភេទ។

ទោះបីជាប្រទេសកម្ពុជាកំពុងមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សក៏ដោយ នៅតាមតំបន់ជនបទមួយចំនួន ភាពក្រីក្រនៅតែមានច្រើននៅឡើយដោយសារ សកម្មភាពចំណូលប្រពៃណីធ្លាក់ចុះ ភាពមិនស្មើភាពក្នុងការទទួលបានកម្មសិទ្ធិ និងលទ្ធភាពទទួលបានទ្រព្យសម្បត្តិរួម ព្រមទាំងបញ្ហាកំណើនប្រជាជន ដែលជាមូលហេតុធ្វើឲ្យប្រព័ន្ធអេកូឡូស៊ីធ្លាក់ក្នុងសភាពទ្រុឌទ្រោម។ អាស្រ័យហេតុនេះ វិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងអភិរក្សគឺត្រូវការជាចាំបាច់។

អង្គការមរតក ជំរុញការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការចូលរួមរបស់សហគមន៍ និងការអភិវឌ្ឍន៍ជីវភាពតាមមធ្យោបាយបង្កើនសមត្ថភាពសគមន៍មូលដ្ឋាន លើកកម្ពស់និរន្តរភាពជីវភាពរស់នៅជនបទ និងដើម្បីសម្រេចបានគោលបំណងគាំពារបរិស្ថាន និងការអភិវឌ្ឍន៍។

គម្រោង "ពង្រឹងជីវភាពសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិនៅជុំវិញឆ្នេរសមុទ្រកំពង់សោម" គ្របដណ្តប់លើការងារអង្គការមរតកក្នុងដំណាក់កាលកម្មវិធីបច្ចុប្បន្ន។ គម្រោងនេះបានទទួលមូលនិធិពីអង្គការ "Bread for the World" ដែលមានមូលដ្ឋាននៅប្រទេសអាឡឺម៉ង់ រួមគ្នាជាមួយនឹងអ្នកផ្តល់មូលនិធិផ្សេងទៀតដែលគ្របដណ្តប់លើការចំណាយនៃគម្រោងតូចៗនៅក្នុងគម្រោងធំជាងនេះ។



*កិច្ចប្រជុំឆ្លុះបញ្ចាំងរបស់គណកម្មកាតសហគមន៍ទុនបង្វិលទាំង១៤និងរៀបចំផែនការសម្រាប់ឆ្នាំបន្ទាប់។*

គោលបំណងគម្រោងនេះគឺ "ប្រជាពលរដ្ឋក្រីក្រក្នុងឃុំចំនួន១៤ជុំវិញឆ្នេរសមុទ្រកំពង់សោម បានធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិ លទ្ធភាពទទួលបានហិរញ្ញវត្ថុសហគមន៍ និងការបង្កើនប្រភពចិញ្ចឹមជីវិតរបស់ពួកគេ។

អង្គការមរតក ធ្វើការជាមួយប្រជាជនក្រីក្រជាង១,០០០០នាក់ ដែលត្រូវបានរៀបចំជាក្រុមចាប់អារម្មណ៍ជាង១៦០ដែលភាគច្រើនជាស្ត្រី (76%)។ ក្រុមចាប់អារម្មណ៍ជាធម្មតាគឺក្រុមអ្នកដាំដំណាំ អាជីវកម្មខ្នាតតូច និងក្រុមអ្នកផលិតផលនេសាទ ឬក្រុមសន្សំ ដែលមានការអារម្មណ៍រួមគ្នា និងរស់នៅក្នុងទីតាំងតែមួយ។ នៅក្នុងឃុំគោលដៅនីមួយៗក្នុងចំណោមឃុំទាំង១៤ ក្រុមចាប់អារម្មណ៍អាចទទួលបានទុកបង្វិលដែលគ្រប់គ្រងដោយសហគមន៍ដើម្បីចាប់ផ្តើមមុខរបរ និងពង្រីក គម្រោងសហគ្រិនរបស់ពួកគេ។ ក្រុមនីមួយៗត្រូវបានតម្រូវឱ្យបង្កើតច្បាប់ផ្ទៃក្នុង បទប្បញ្ញត្តិ និងផែនការអាជីវកម្ម។

ទីផ្សារផលិតផលសហគមន៍ត្រូវបានគាំទ្រតាមរយៈបណ្តាញអាជីវកម្មសហគមន៍ ដែលជួយអ្នកផលិតឱ្យអនុវត្តតាមស្តង់ដារផលិតកម្មរួម និងការវេចខ្ចប់តាមស្តង់ដារ និងស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ពួកគេ។ ឥឡូវនេះ អង្គការមរតកកំពុងជួយបណ្តាញអាជីវកម្មដើម្បីទទួលបានឋានៈជាផ្លូវការជាសហករណ៍កសិកម្ម។

អង្គការមរតក ក៏ធ្វើការជាមួយអង្គការតាមសហគមន៍ចំនួន១៩ដែលធ្វើការលើការគ្រប់គ្រងធនធានធម្មជាតិដែលគ្របដណ្តប់លើផ្ទៃដី58,922ហិកតារួមមានៈ សហគមន៍នេសាទចំនួន៨ សហគមន៍ព្រៃឈើចំនួន៣និងសហគមន៍តំបន់ការពារចំនួន៨។ ក្រុមទាំងនេះដំណើរការស្របតាមតម្រូវការរៀងៗខ្លួនរបស់រដ្ឋបាលជលផលរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន។ ក្រុមសហគមន៍ទាំងនោះរួមមានមេដឹកនាំជាប់ឆ្នោតប្រហែល១៨០នាក់ (ក្នុងនោះប្រហែល២០%ជាស្ត្រី) និងមានសមាជិកប្រហែល២៤,២០០នាក់ (រួមទាំងស្ត្រីនិងក្មេងស្រីប្រមាណ១២,២០០នាក់) ជាសមាជិកទទួលបានអត្ថប្រយោជន៍ដោយប្រយោល ឬដោយផ្ទាល់ពីការប្រើប្រាស់ធនធានធម្មជាតិ ទេសចរណ៍ធម្មជាតិ នេសាទ និងប្រមូលផលអនុផលព្រៃឈើ។


*ប្រជុំជ្រើសរើសគណកម្មការសហគមន៍តំបន់ការពារភ្នំទ័ព្វជាងសម្រាប់ឆ្នាំ ២០២០ ដល់២០២៤*

គម្រោងដែលដំណាក់កាលបច្ចុប្បន្នមានលទ្ធផលចំនួន៣៖

- បានពង្រឹងសមត្ថភាពអ្នកផលិតខ្នាតតូចដើម្បីបង្កើនការផលិត និងនាំផលិតផលទៅកាន់ទីផ្សារ ។
- អ្នកផលិតខ្នាតតូចទទួលបានហិរញ្ញវត្ថុសហគមន៍ដើម្បីធ្វើឱ្យប្រសើរឡើងការផលិត។
- សហគមន៍ចំនួន១៩ក្នុងឃុំចំនួន១៤ជុំវិញឆ្នេរសមុទ្រកំពង់សោមបានកែលម្អការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

គិតត្រឹមខែធ្នូ ឆ្នាំ 2022 គម្រោងនេះបានទទួលលទ្ធផលដូចខាងក្រោម៖

- ✓ 67% នៃគ្រួសារក្រីក្រដែលចូលរួម (762 គ្រួសារ) ក្នុងចំណោមគ្រួសារសរុប១,១៤៤បានបង្កើនប្រភពចិញ្ចឹមជីវិតរបស់ពួកគេតាមរយៈការអនុវត្តគម្រោងចិញ្ចឹមជីវិត បានទទួលជោគជ័យរកប្រាក់ចំណេញ។ ក្នុងនោះ77% នៃសមាជិកក្រុមចាប់អារម្មណ៍រកប្រាក់ចំណេញគឺជាស្ត្រី។
- ✓ សហគមន៍ចំនួន១៣ទទួលបានការយល់ព្រមជាផ្លូវការសម្រាប់អនុវត្តន៍ផែនការរបស់ពួកគេដើម្បីការពារ និងប្រើប្រាស់ធនធានធម្មជាតិ។ ក្នុងនោះរួមមានសហគមន៍នេសាទទាំង៨ សហគមន៍២ក្នុងចំណោមព្រៃឈើទាំង៣ (សាមគ្គីព្រែកជីក និងអ្នកតាថ្មព្រង់) និងសហកមន៍៣ ក្នុងចំណោមសហគមន៍តំបន់ការពារទាំង៨ (អណ្តូងទឹក ជីខលើ និងភ្នំទ័ព្វជាង)។
- ✓ ទោះបីជាផែនការគ្រប់គ្រង និងផែនការសកម្មភាពប្រចាំឆ្នាំរបស់សហគមន៍មួយចំនួននៅមិនទាន់មានការយល់ព្រមពេញលេញពីអាជ្ញាធរក៏ដោយ បុគ្គលិកកម្មវិធីរបស់អង្គការមរតក បាននិងកំពុងគាំទ្រសហគមន៍ទាំង១៩ដើម្បីអនុវត្តសកម្មភាពដូចជា ការចុះល្បាតទប់ស្កាត់អំពើខុសច្បាប់ និងនិរន្តរភាពទទួលបានអត្ថប្រយោជន៍ពីធនធានធម្មជាតិ។

ក្នុងដំណាក់កាលបន្ទាប់នៃគម្រោងឆ្នាំ២០២៣អង្គការមរតកមានបំណងផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភគាំទ្រដល់ជនពិការ និងចាប់ផ្តើមការងារថ្មីលើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

## សហគមន៍រស់នៅជុំវិញឆ្នេរសមុទ្រកំពង់សោម

នៅខែមករា ឆ្នាំ២០២២ អង្គការមរតកបានចាប់ផ្តើមគម្រោងរយៈពេល៤ឆ្នាំដែលផ្តល់មូលនិធិដោយ FELM ដែលមានគោលបំណងពង្រឹងលើការងារសន្តិសុខស្បៀង ការគ្រប់គ្រងធនធានធម្មជាតិ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅក្នុងឃុំចំនួន៨ឃុំ។ FELM គឺជាទីភ្នាក់ងារប្រតិបត្តិនៃអង្គការសាសនានៅប្រទេសហ្វាំងឡង់"Evangelical Lutheran" ដែលធ្វើការដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងយុត្តិធម៌នៅជុំវិញពិភពលោក។

គម្រោងឈ្មោះ "សហគមន៍មានធន់ទៅនឹងការប្រែប្រួលអាកាសធាតុជុំវិញឆ្នេរសមុទ្រកំពង់សោម" ផ្តោតលើឃុំចំនួន៨ នៅជុំវិញឆ្នេរសមុទ្រកំពង់សោម មានគោលបំណងចំនួន ៣៖

- ប្រជាជនក្រីក្រក្នុងឃុំចំនួន៨ជុំវិញឆ្នេរសមុទ្រកំពង់សោមបានកែលម្អជីវភាពរបស់ពួកគេ តាមរយៈបង្កើនប្រាក់ចំណូល និងលើកកម្ពស់សន្តិសុខស្បៀង ។
- សហគមន៍ក្នុងឃុំចំនួន៨ជុំវិញឆ្នេរសមុទ្រកំពង់សោម បានការពារធនធានជលផល ព្រៃកោងកាង និងធនធានធម្មជាតិផ្សេងទៀត ដោយសហការជាមួយអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាល។
- សហគមន៍ក្នុងឃុំចំនួន៨នៅជុំវិញឆ្នេរសមុទ្រកំពង់សោមបានដាក់ចេញនូវវិធានការសម្រាប់ការបន្សាំអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដោយសហការជាមួយស្ថាប័នសិក្សា និងមន្ត្រីរដ្ឋាភិបាល។

ការបង្កើនជីវភាពប្រជាសហគមន៍តាមរយៈលើកកម្ពស់ សន្តិសុខស្បៀងនិងបង្កើនប្រាក់ចំណូលមានគោលបំណងកាត់បន្ថយការពឹងផ្អែកលើការកេងប្រវ័ញ្ចលើធនធានធម្មជាតិហួសហេតុ។ កិច្ចការទាំងនេះនឹងត្រូវធ្វើ ទី១ ការលើកកម្ពស់សកម្មភាពកសិកម្មបន្ទាប់បន្សំ (ក្រៅពីការធ្វើស្រែ) ដូចជាការចិញ្ចឹមជ្រូកមាន់ទា និងការផ្តួចផ្តើមសួនបន្លែតាមផ្ទះ ទី២ ការលើកកម្ពស់អាជីវកម្មខ្នាតតូចមិនមែនកសិកម្ម និងទី៣ ការបន្ថែមតម្លៃដល់ផលិតផលប្រកបដោយនិរន្តរភាព ឧ៖ផលិតទឹកត្រី ទឹកត្រីផលិតផលផ្គៅ និងទឹកឃ្មុំព្រៃ តាមរយៈការកែលម្អបច្ចេកទេសកែច្នៃ ការកំណត់ស្តង់ដារវេចខ្ចប់ និងកំណត់ទីផ្សារ។

គម្រោងនេះកំពុងពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទទាំង៨ និងគណៈកម្មាធិការសហគមន៍តំបន់ការពារ (CPA) ចំនួន៤ ដើម្បីការពារតំបន់ជលផល និងតំបន់ព្រៃកោងកាងរៀងៗខ្លួន។ កិច្ចការនេះនេះរួមបញ្ចូលទាំងការរៀបចំផែនការគ្រប់គ្រងការលើកកម្ពស់ការយល់ដឹងនៅថ្នាក់ភូមិ និងការគាំទ្រសម្រាប់ការងារល្បាត និងការផ្តល់ឧបករណ៍ល្បាតដើម្បីការពារធនធានធម្មជាតិ។

ចំណុចសំខាន់ៗនៃគម្រោងក្នុងឆ្នាំ២០២២រួមមាន:

- ✓ សហគមន៍នេសាទចំនួន៨បានទទួលការកសាងសមត្ថភាពចំណេះដឹងលើផ្លូវច្បាប់ NRM និងអំពីរបៀបគ្រប់គ្រងប្រចាំឆ្នាំរបស់ពួកគេ ព្រមទាំងបានធ្វើការល្បាតជាប្រចាំដើម្បីការពារការនេសាទខុសច្បាប់។
- ✓ ក្រុមសហគមន៍នេសាទបានដាំកូនដើមកោងកាងចំនួន២០០០ដើមនៅជ្រោយស្វាយ និងដើមកោងកាងចំនួន៣.៥០០នៅថ្មស។
- ✓ ក្រុមល្បាតនៃសហគមន៍តំបន់ការពារទាំង៤បានចុះល្បាតយ៉ាងហោចណាស់ពីរដងក្នុងមួយខែ ដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងព្រៃកោងកាង។
- ✓ ប្រជាពលរដ្ឋចំនួន១០១នាក់ បានទទួលការបណ្តុះបណ្តាល និងបានចូលរួមទស្សនកិច្ចផ្លាស់ប្តូរយោបល់លើការកែច្នៃផលិតផលគ្រឿងសមុទ្រ ដូចជា បង្គា ត្រីប្រែ និងត្រីស្ងួត។

ប៉ុន្មានឆ្នាំខាងមុខ គម្រោងនេះក៏នឹងសហការជាមួយក្រុមប្រឹក្សាឃុំចំនួន ៨ និងសហគមន៍ពាក់ព័ន្ធដើម្បីបង្កើតផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងសហការជាមួយទីប្រឹក្សា ឬនិងនិស្សិតសាកលវិទ្យាល័យដើម្បីធ្វើការស្រាវជ្រាវលើ តម្រូវការកាត់

បន្ថយការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ។ គម្រោងនេះនឹងសាកល្បងវិធានការកាត់បន្ថយផ្សេងៗដែលត្រូវបានណែនាំដោយការស្រាវជ្រាវ។

## ការពង្រឹងសហគមន៍លើការគ្រប់គ្រងធនធានធម្មជាតិ និងប្រើប្រាស់ធនធានដោយនិរន្តរភាព

គម្រោងមួយនេះ ក៏ទទួលបានការឧបត្ថម្ភពីមូលនិធិពិភពលោកសម្រាប់ធម្មជាតិ (WWF) មានគោលបំណងពង្រឹងការងារអង្គការមរតកជាមួយនឹងសហគមន៍ព្រៃឈើចំនួន២និងសហគមន៍តំបន់ការពារចំនួន៣ ដែលជាផ្នែកមួយនៃគម្រោងWWFស្តីពី "ការដឹកនាំដើម្បីការផ្លាស់ប្តូរ សិទ្ធិសង្គមស៊ីវិល និងបរិស្ថាន"។



*សកម្មភាពសមាជិកក្រុមកែច្នៃផ្តៅ/ឫស្សីនៃសហគមន៍តំបន់ការពារភ្នំទ័ព្វជាងតំលើងធុងទឹកធ្វោះពីផ្តៅ/ឫស្សី*

សហគមន៍ព្រៃឈើត្រូវបានចុះបញ្ជីជាមួយរដ្ឋបាលព្រៃឈើ ចំណែកសហគមន៍តំបន់ការពារ (CPAs) ត្រូវបានចុះបញ្ជីជាមួយក្រសួងបរិស្ថាន។ អង្គការសហគមន៍មូលដ្ឋានទាំងនេះ គ្រប់គ្រងធនធានធម្មជាតិសម្រាប់ជាប្រយោជន៍សហគមន៍ប្រកបដោយនិរន្តរភាព។

គោលបំណងនៃគម្រោងគឺ "អង្គការសហគមន៍ចំនួន៥ ជុំវិញឆ្នេរសមុទ្រកំពង់សោមគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងកាត់បន្ថយសម្ពាធរបស់មនុស្សលើធនធានធម្មជាតិ តាមរយៈគំនិតផ្តួចផ្តើមមុខរបរចិញ្ចឹមជីវិតដែលបន្សាំនឹងអាកាសធាតុប្រែប្រួល។

គម្រោងនេះមានគោលបំណងកសាងសមត្ថភាពសហគមន៍ទាំង៥សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាព និងបង្កើនប្រាក់ចំណូលតាមរយៈការដកហូតនិងកែច្នៃអនុផលព្រៃឈើ (NTFP) និងសកម្មភាពចិញ្ចឹមជីវិតផ្សេងទៀត។ មានសមាជិកសហគមន៍ចំនួន១,៥៥០គ្រួសារទទួលបានអត្ថប្រយោជន៍ពីគម្រោង ក្នុងដែនការពារព្រៃឈើចំនួន៥,៥០៦ហិកតា។

គម្រោងនេះមានគោលបំណង២៖

- ទី១ សហគមន៍ទាំង៥ បានប្រើប្រាស់សមត្ថភាពរបស់ពួកគេដើម្បីកែលម្អការអនុវត្តផែនការគ្រប់គ្រងទាក់ទងនឹងការការពារ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- ទី២ សមាជិកសហគមន៍ទាំង៥ បានបង្កើនប្រាក់ចំណូលគ្រួសារតាមរយៈការចូលរួមក្នុងការកែច្នៃអនុផល និងបន្ថែមខ្សែសង្វាក់តម្លៃ ដើម្បីចូលទៅកាន់ទីផ្សារ និងខ្សែសង្វាក់តម្លៃផលិតកម្មកសិកម្មផ្សេងៗ។

ខាងក្រោមនេះគឺជាសមិទ្ធផលរបស់គម្រោងឆ្នាំ២០២២៖

- ✓ សហគមន៍ព្រៃឈើព្រែកជីកនៅឃុំជីខក្រោម ទទួលបានការយល់ព្រមជាផ្លូវការពីថ្នាក់ជាតិ រីឯភ្នំទ័ព្វជាង និងសហគមន៍ព្រៃឈើអ្នកតាថ្មព្រង់បានទទួលការយល់ព្រមពីថ្នាក់ខេត្ត ខណៈដែលសហគមន៍ចំនួនពីរផ្សេងទៀតគឺជ្រោយស្វាយ និងព្រែកចំការក្រោម បានឈានដល់ជំហានទី៦ នៃដំណើរការរៀបចំផែនការទាំង៨ជំហាន។
- ✓ បច្ចុប្បន្ននេះភ្នំទ័ព្វជាងបានបែងចែកប្រាក់ចំណូលពីការលក់អនុផលព្រៃឈើនិងសេវាកម្មទេសចរណ៍ធម្មជាតិ ដល់ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- ✓ មាន៨០គ្រួសារនៅក្នុងសហគមន៍ភ្នំទ័ព្វជាង និងភូមិក្រាំងអាត់ (ក្នុងឃុំចំនួន២) ទទួលបានប្រាក់ចំណូលជាមធ្យម 387 ដុល្លារក្នុងមួយគ្រួសារពីការលក់អនុផលព្រៃឈើក្នុងឆ្នាំ២០២២។

ដោយផ្អែកលើសកម្មភាពក្នុងផែនការយុទ្ធសាស្រ្តថ្មីសម្រាប់រយៈពេល៥ឆ្នាំ (២០២៣-២០២៨) អង្គការមរតកនឹងចាប់ផ្តើមដំណាក់កាលថ្មីនៃការគាំទ្រថវិការពីWWF នៅខែកក្កដា ឆ្នាំ 2023 (សូមមើលទំព័រ១១) ។

## ករណីសិក្សា "ការលើកកម្ពស់ជីវភាព"

*ផ្អែកលើការសម្ភាសន៍សហគមន៍ដែលបានធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ 2023*



*Ms. KOUY Sothea, examining the community revolving fund's business records.*

អ្នកស្រី គួយ សុធា មានប្រសាសន៍ថា "ខ្ញុំជាស្ត្រីមេផ្ទះ មានកូន ៤នាក់។ "កាលពីមុន យើងក្រីក្រ អត់មានអាហារហូបគ្រប់គ្រាន់ ព្រោះប្តីខ្ញុំ និងខ្ញុំមិនមានជំនាញគ្រប់គ្រាន់ដើម្បីរកប្រាក់ចំណូលបានសមរម្យ។

"ក្រោយមក ខ្ញុំបានក្លាយជាសមាជិកនៃមូលនិធិទុនបង្វិលរបស់សហគមន៍ ដែលគាំទ្រដោយអង្គការមរតក ។ ខ្ញុំអាចទទួលបានប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូចរបស់ខ្ញុំ ហើយជីវភាពរបស់ខ្ញុំបានប្រសើរឡើង។ ខ្ញុំត្រូវបានសហគមន៍ ជ្រើសរើសឲ្យធ្វើជាប្រធានមូលនិធិទុនបង្វិលសហគមន៍ក្នុងឃុំរបស់ខ្ញុំ។ អង្គការមរតក បានបណ្តុះបណ្តាលខ្ញុំអំពីរបៀបគ្រប់គ្រងបញ្ជីចំណូល និងចំណាយ របៀបបង្កើតផែនការអាជីវកម្ម និងវិធីបង្កើនជំនាញភាពជាអ្នកដឹកនាំដល់ខ្ញុំ។

"ថ្មីៗនេះ អង្គការមរតកបានជួយយើងចាប់ផ្តើមមជ្ឈមណ្ឌលអាជីវកម្មសហគមន៍។ នៅក្នុងមជ្ឈមណ្ឌលយើងដំណើរការផលិតគ្រឿងសមុទ្រ និងសម្របសម្រួលរកទីផ្សារនៃផលិតផល ។ ខ្ញុំបានចាត់ចែងដឹកនាំក្រុម និងចែកចាយប្រាក់ចំណូលដល់សមាជិកទាំង៤៣នាក់ ដែលភាគច្រើនជាស្ត្រីប្រកបដោយតម្លាភាព និងគណនេយ្យភាព។

## តារាងរចនាសម្ព័ន្ធអង្គការអង្គការមរតក



នៅឆ្នាំ២០២២ អង្គការមរតកបានបង្កើតផែនការយុទ្ធសាស្រ្តថ្មីសម្រាប់រយៈពេល 2023 ដល់ 2028។ គោលដៅអភិវឌ្ឍន៍ ដែលកម្មវិធីថ្មីនឹងរួមចំណែកគឺ៖

"សហគមន៍នៅតំបន់ឆ្នេរសមុទ្រភាគនិរតីប្រទេសកម្ពុជាមានភាពធន់ជាងមុនតាមរយៈការលើកកម្ពស់ជីវភាពរស់នៅ ការគ្រប់គ្រងធនធានធម្មជាតិ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ"។




ដើម្បីគាំទ្រដល់គោលដៅនេះ កម្មវិធីកានេះបានផ្តោតលើលទ្ធផល 3៖

លទ្ធផលទី១៖ សន្តិសុខស្បៀងរបស់គ្រួសារក្រីក្រដែលកំណត់ដោយកម្មវិធីត្រូវបានកែលម្អ។

លទ្ធផលទី២៖ សហគមន៍ក្នុងឃុំចំនួន១៤ ជុំវិញឆ្នេរសមុទ្រកំពង់សោម បានការពារធនធានជលផល ព្រៃឈើ និងធនធានធម្មជាតិផ្សេងទៀត ដោយសហការជាមួយអាជ្ញាធរមន្ត្រីរដ្ឋាភិបាល។

លទ្ធផលទី៣៖ សហគមន៍ក្នុងឃុំចំនួន១៤ ជុំវិញឆ្នេរសមុទ្រកំពង់សោម បានដាក់ចេញនូវវិធានការសម្រាប់ការបន្សាំអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដោយសហការជាមួយក្រុមប្រឹក្សាឃុំ។

ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ មរតក គឺ៖

ប្រសិនបើ អង្គការមរតកផ្តល់ឱ្យអ្នកដឹកនាំសហគមន៍នូវការបណ្តុះបណ្តាល និងធនធានសមស្រប និងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងអ្នកដឹកនាំសហគមន៍ និងមន្ត្រីមូលដ្ឋាន។

**បន្ទាប់មក** អ្នកដឹកនាំសហគមន៍នឹងប្រើប្រាស់ការបណ្តុះបណ្តាល និងធនធាននេះ ដើម្បីជួយសម្រួលដល់សកម្មភាពសហគមន៍សម្រាប់ការអភិវឌ្ឍជីវភាពរស់នៅកាន់តែប្រសើរឡើង ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្សាំអាកាសធាតុ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន។

<u>លទ្ធផលខាងលើអាចកើតឡើងដោយសារតែ</u> អ្នកដឹកនាំសហគមន៍គឺជាមនុស្សដែលមានចិត្តខិតខំប្រឹងប្រែងហានលះបង់ពេលវេលា ដើម្បីកែលម្អស្ថានភាពសហគមន៍និងបរិស្ថានរបស់ពួកគេ ហើយមានឆន្ទៈយកចំណេះដឹងដែលទទួលបានពីការងារបណ្តុះបណ្តាល និងធនធានដែលពួកគេទទួលបានបន្តអនុវត្តភារកិច្ចរបស់គេ។

ទោះបីជាមានស្ថានភាពអវិជ្ជមានផ្នែកសេដ្ឋកិច្ច សម្ពាធន៍បរិយាកាសក្នុងសហគមន៍និងស្ថាប័ន ដែលអាចប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ដោយ ក៏អ្នកដឹកនាំសហគមន៍ខ្លួនឯងគឺជាអ្នកដែលមានការលើកទឹកចិត្តដ៏ល្អបំផុតអាចកំណត់ និងអនុវត្តនូវដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ។

អាជ្ញាធរមូលដ្ឋានមានកាតព្វកិច្ចខាងផ្លូវច្បាប់ក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍  ដោយផ្អែកលើច្បាប់  និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយពួកគេចាំបាច់ត្រូវចូលរួមនៅក្នុងដំណើរការនេះ។

តំបន់គោលដៅគម្រោងសម្រាប់ដំណាក់កាលថ្មីបានបង្ហាញនៅលើផែនទីខាងក្រោម៖ (មិនមានការផ្លាស់ប្តូរទេ)

**Morodok Target Areas and Community-Based Organisations**




**Legend**

Communes funded only by Bread for the World

Communes with co-funding from FELM

CFi Community Fisheries

CFo Community Forest

CPA Community Protected Area

CPA Community-based organisations with co-funding from WWF are underlined

# របាយការណ៍ ហិរញ្ញវត្ថុ

## ព័ត៌មានស្ដីពីការទទួលមូលនិធិ ការដកប្រាក់ និងសមតុល្យមូលនិធិសម្រាប់ឆ្នាំ២០២២

| | ដុល្លារអាមេរិក | ០០០ រៀល |
|---|---|---|
| **បង្កាន់ដៃមូលនិធិ** | | |
| ផ្ដល់ប្រាក់ចំណូល | ២៦៥.៨៧០ | ១.០៨៦.៦១២ |
| **បង្កាន់ដៃសរុប** | **២៦៥.៨៧០** | **១.០៨៦.៦១២** |
| **ការដកប្រាក់** | | |
| ការទូទាត់ប្រតិបត្តិការតាមផ្នែកនៃគម្រោងកម្មវិធី | | |
| ផ្នែក១៖ គម្រោង ជីវភាព និងសន្តិសុខស្បៀង | ២០.២១៦ | ៨២.៦២៤ |
| ផ្នែក២៖ គម្រោងគ្រប់គ្រងធនធានធម្មជាតិ | ៣៣.៩២៥ | ១៣៨.៦៥០ |
| ការចំណាយផ្ទាល់របស់គម្រោង | ៣១.៥១៤ | ១២៨.៧៩៧ |
| ប្រាក់ខែបុគ្គលិក និងអត្ថប្រយោជន៍ | ៦៥.២២៦ | ២៦៦.៥៨១ |
| ការត្រួតពិនិត្យ និងវាយតម្លៃ | ១៣.២០០ | ៥៣.៩៤៩ |
| ចំណាយរដ្ឋបាល | ៤.៤៤៧ | ១៨.១៧៤ |
| ការត្រួតពិនិត្យការគ្រប់គ្រង / ហិរញ្ញវត្ថុ | ៩.៩២៦ | ៤០.៥៦៩ |
| ប្រាក់ខែបុគ្គលិករដ្ឋបាល/ហិរញ្ញវត្ថុ | ២៤.៣៤២ | ៩៩.៤៨៥ |
| អត្ថប្រយោជន៍បុគ្គលិកផ្នែករដ្ឋបាល/ហិរញ្ញវត្ថុ | ២.១៤៥ | ៨.៧៦៨ |
| ការសម្របខ្លួនទៅនឹងអាកាសធាតុ | ៧៨៤ | ៣.២០៦ |
| **ការទូទាត់ប្រតិបត្តិការសរុប** | **២០៥.៧២៦** | **៨៤០.៨០២** |
| **បង្កាន់ដៃឱនភាពសម្រាប់ឆ្នាំ** | ៦០.១៤៤ | ២៤៥.៨១០ |
| សមតុល្យមូលនិធិបាននាំមក | ៣៤.៥៣១ | ១៣៨.១២៥ |
| ភាពខុសគ្នានៃការបកប្រែរូបិយប័ណ្ណ | | ៥.៨៤៥ |
| **សមតុល្យមូលនិធិ** | **៩៤.៦៧៦** | **៣៨៩.៧៨០** |
| ***តំណាងដោយ៖*** | | |
| សាច់ប្រាក់ និងសមមូលសាច់ប្រាក់ | ៩៤.៦៧៦ | ៣៨៩.៧៨០ |
| | **៩៤.៦៧៦** | **៣៨៩.៧៨០** |

អង្គការមរតក

MORODOK ORGANIZATION

បោះពុម្ពនៅទីក្រុងភ្នំពេញ
© អង្គការមរតក ឆ្នាំ២០២៣